# គោលជំហររួមរបស់សមាគម_អង្គការមិនមែនរដ្ឋាភិបាល ស្តីពី
# សេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

យើងខ្ញុំទាំងអស់គ្នា ជាតំណាងសហគមន៍អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ អង្គការមហាជននៅតាមសហគមន៍ និងសមាគមទាំងអស់ សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការចែករំលែកសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដល់យើងខ្ញុំទាំងអស់គ្នា ដើម្បីជជែកពិភាក្សានៅមុនសិក្ខាសាលានៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។ ជាមួយនឹងពេលវេលាដែលបានកំណត់ឱ្យ យើងខ្ញុំទាំងអស់គ្នាបានខិតខំប្រឹងប្រែងពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ ព្រមទាំងបានឯកភាពគ្នាស្នើសុំដល់រាជរដ្ឋាភិបាល ឱ្យពិនិត្យពិចារណាលើចំណុចមួយចំនួន ដែលយើងខ្ញុំទាំងអស់គ្នាបានសង្ខេបបញ្ចូលគ្នា ដូចដែលបានភ្ជាប់មកជាមួយ ។

អង្គការមិនមែនរដ្ឋាភិបាលមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច សុខាភិបាល អប់រំ យុត្តិធម៌ និងវិស័យផ្សេងៗជាច្រើនទៀត។ តួនាទីនេះមានលក្ខណៈពិសេសដោយផ្តោតផ្ទាល់ទៅលើសុខមាលភាពសាធារណៈ និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្សេងៗដែលវិស័យឯកជន ឬរដ្ឋមិនអាចបំពេញបាន។ អង្គការមិនមែនរដ្ឋាភិបាល ក៏បានផ្តល់ផលប្រយោជន៍ផងដែរដល់វិស័យសេដ្ឋកិច្ចដោយបានផ្តល់ការងារ និងបណ្តុះបណ្តាលប្រជាជនកម្ពុជានៅទូទាំងប្រទេស ក៏ដូចជានាំមកនូវទឹកប្រាក់រាប់រយលានដុល្លារសហរដ្ឋអាមេរិកក្នុងមួយឆ្នាំៗ ក្នុងការអនុវត្តគម្រោង និងកម្មវិធីជួយដល់ប្រជាជនកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាលបរទេស ក៏បាននាំមកនូវធនធានដ៏ចាំបាច់ និងចំណេះដឹងជាច្រើនដល់ព្រះរាជាណាចក្រកម្ពុជា។

ប៉ុន្តែ ខ្លឹមសារនៃសេចក្តីព្រាងច្បាប់បច្ចុប្បន្ន នឹងរឹតបន្តឹងដល់ការងាររបស់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់នេះ ពីព្រោះ វាបង្កើតជាឧបសគ្គចំបងនៅក្នុងការចុះបញ្ជី និងការអនុវត្តសកម្មភាពរបស់ពួកគេ។ ផលវិបាក ដែលកើតចេញពីច្បាប់នេះ គឺបានធ្វើឱ្យថយចុះនូវការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍន៍គម្រោងសំខាន់ៗជាច្រើន ដែលបាននឹងកំពុងអនុវត្តដោយសហការជាមួយរាជរដ្ឋាភិបាលនៅពេលបច្ចុប្បន្ន ហើយកាត់បន្ថយប្រភពមូលនិធិ ដែលគ្រោងនឹងផ្តល់ឱ្យថ្មីទៀតសម្រាប់ការអភិវឌ្ឍន៍រយៈពេលយូរអង្វែងផងដែរ។ ក្នុងន័យនេះ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ទាំងអស់មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីផលវិបាកដែលអាចនឹងកើតមានឡើង នៅពេលដែលច្បាប់នេះ ត្រូវបានអនុម័ត និងចូលជាធរមាន ប្រសិនបើគ្មានការកែប្រែនោះទេ។

ចំណុចសំខាន់ដែលយើងខ្ញុំមានការព្រួយបារម្ភគឺ:

១. ការប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

២. ភាពស្មុគស្មាញលើលក្ខខណ្ឌនៃការចុះបញ្ជី និងកាតព្វកិច្ចមិនចាំបាច់នៃការបញ្ជូនរបាយការណ៍ និងសវនកម្ម

៣. ភាពមិនច្បាស់លាស់នៃអត្ថន័យរបស់ពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងច្បាប់

លើសពីនេះទៀត សេចក្តីព្រាងច្បាប់នេះអាចបន្ថែមបន្ទុកការងារដល់ភ្នាក់ងាររបស់រាជរដ្ឋាភិបាលដែលនឹងអនុវត្តច្បាប់ថ្មីនេះ ជាពិសេស ក្រសួងមហាផ្ទៃ និង ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ វានឹងជួយដល់រាជរដ្ឋាភិបាល ប្រសិនបើពាក្យពេចន៍ទាំងអស់ត្រូវបានចែងឱ្យច្បាស់ និងធ្វើឱ្យដំណើរការចុះបញ្ជី និងរបាយការណ៍មានលក្ខណៈសាមញ្ញ។ ភាពសាមញ្ញនេះ នឹងជួយកាត់បន្ថយបន្ទុកការងាររដ្ឋបាលដល់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមហាជននៅតាមសហគមន៍ នៅខេត្ត-ក្រុង ដែលមានលក្ខណៈតូចតាច និងដែលជាភ្នាក់ងារសំខាន់សម្រាប់ការអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព នៅប្រទេសកម្ពុជា។

យើងខ្ញុំយល់អំពីសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាល ក្នុងការបង្កើតឱ្យមានក្របខណ្ឌច្បាប់មួយ ដើម្បីធានានូវស្ថិរភាព និងសន្តិសុខសង្គម ក៏ដូចជា ដើម្បីធានាឱ្យជំនួយអភិវឌ្ឍន៍ និងមនុស្សធម៌បានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ប៉ុន្តែ សេចក្តីត្រូវការនៃក្របខណ្ឌច្បាប់នេះ ក៏ត្រូវធានាឱ្យមានផងដែរនូវសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការចូលរួមនៅក្នុងសកម្មភាពស្របច្បាប់ដោយគ្មានការរឹតត្បិត។ មាត្រា ២នៃសេចក្តីព្រាងច្បាប់នេះឆ្លើយតបនឹងគោលគំនិតខាងលើផងដែរ ដោយចែងថា "*ច្បាប់នេះមានគោលបំណងលើកកម្ពស់ការអនុវត្តសិទ្ធិ សេរីភាព របស់ប្រជាពលរដ្ឋខ្មែរក្នុងការបង្កើតសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីរួមគ្នាការពារផលប្រយោជន៍ ស្របច្បាប់របស់ខ្លួន និងផលប្រយោជន៍សាធារណៈ។*"

ដើម្បីឆ្លើយតបនឹងកង្វល់ខាងលើ យើងខ្ញុំសូមទទូចដោយដល់រាជរដ្ឋាភិបាល មេត្តាពិចារណាសំណូមពររបស់យើងខ្ញុំដូចខាងក្រោមៈ

- គួរតែចាត់ទុក កិច្ចពិភាក្សាថ្នាក់ជាតិដែលរៀបចំដោយក្រសួងមហាផ្ទៃ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ជាដំណាក់កាលទី១ នៃការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ហើយរាជរដ្ឋាភិបាល គួរតែអនុញ្ញាតឱ្យមានការពិភាក្សាជាបន្តបន្ទាប់ទៀត ។
- គួរបង្កើតឱ្យមានក្រុមការងារមួយ ដែលមានតំណាងរាជរដ្ឋាភិបាល និងតំណាងសង្គមស៊ីវិល ដើម្បីចូលរួមពិភាក្សាលើបញ្ហា និងការព្រួយបារម្ភ ដែលបានលើកឡើងក្នុងរបាយការណ៍សង្ខេបបញ្ចូលគ្នារបស់អង្គការមិនមែនរដ្ឋាភិបាល។

យើងខ្ញុំសុំជូនភ្ជាប់ជាមួយនូវរបាយការណ៍សង្ខេបបញ្ចូលគ្នា ដែលបញ្ជាក់ពីជំហររួមរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួនជាង៥០០។ របាយការណ៍សង្ខេបនេះ ឆ្លើយតបនឹងឆន្ទៈរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដែលបាននឹងកំពុងប្រតិបត្តិការនៅប្រទេសកម្ពុជា ដើម្បីចូលរួមធ្វើឱ្យប្រសើរឡើងនូវសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ អ្នកចូលរួមផ្តល់មតិទាំងអស់បានទទួលស្គាល់នូវផលប៉ះពាល់ពិតប្រាកដលើកិច្ចអភិវឌ្ឍន៍នៅប្រទេសកម្ពុជា ប្រសិនបើសេចក្តីច្បាប់នេះ ចូលជាធរមានដោយពុំមានការកែប្រែនោះទេ។ ដូច្នេះ យើងខ្ញុំទាំងសូមស្នើឱ្យមានការពិគ្រោះយោបល់យ៉ាងស៊ីជម្រៅជាមួយភាគីពាក់ព័ន្ធទាំងអស់។

យើងខ្ញុំទាំងអស់គ្នា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុនចំពោះការពិចារណា និង ការយោគយល់របស់រាជរដ្ឋាភិបាល ទៅលើសំណើរបស់យើងខ្ញុំ។

ភ្នំពេញ ថ្ងៃទី ០៥ មករា ឆ្នាំ ២០១១

តំណាងឱ្យអង្គការជាតិ និង អន្តរជាតិនៅក្នុងប្រទេសកម្ពុជា

-គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

-វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

-អង្គការមេឌីខាំ

-គណៈកម្មាធិការប្រព្រឹត្តកម្មនៃ អង្គការ-សមាគម ការពារសិទ្ធិមនុស្សកម្ពុជា